## **គាថាទី ១**[១] *( កាសែតទី ០៣B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុដែលគេប្រដៅបានដោយលំបាកមួយរូប ទើបត្រាស់នូវព្រះគាថានេះថា

**កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ**
**សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយូបកឌ្ឍតិ។**
**យំ កិញ្ចិ សិថិលំ កម្មំ សង្កិលិដ្ឋញ្ច យំ វតំ**
**សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ។**
**កយិរា ចេ កយិរាថេនំ ទឡ្ហមេនំ បរក្កមេ**
**សិថិលោ ហិ បរិព្វាជោ ភិយ្យោ អាកិរតេ រជំ។**

ស្បូវភ្លាំង ដែលបុគ្គលកាន់មិនចំណាប់ រមែងលះដៃ យ៉ាងណាមិញ ភាពជាសមណៈដែលបព្វជិត

---

១-បើរាប់តាមលំដាប់ក្នុងនិរយវគ្គ ត្រូវជាគាថា ទី ៥

កាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះទៅនរក យ៉ាងនោះឯង ។

កម្មណាមួយ ដែលធូរថយក្តី វ័តណាមួយដែលសៅហ្មងក្តី ព្រហ្មចរិយៈដែលបុគ្គលរឭកដោយសេចក្តីរង្កៀសក្តី កម្មទាំង ៣ នោះ ជារបស់មិនមានផលច្រើនឡើយ ។

បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឱ្យមែនទែន គប្បីប្រឹងប្រែងធ្វើកិច្ចនោះឱ្យមាំមួន ព្រោះថា សមណធម៌ជាគ្រឿងវៀរចាកកិលេសធូរថយ រមែងរោយធូលីគឺរាគាទិក្កិលេស ដល់បុគ្គលដោយក្រៃលែង ។

# បទព្រហ្មគីតិ

បុគ្គលគ្មានកម្លាំង    ចាប់ស្បូវភ្លាំងមិនចំណាប់
ស្បូវភ្លាំងពិតត្រឡប់    មកលះដៃវិញមិនខាន ។
យ៉ាងណាភេទសមណៈ    ដែលអ្នកបួសកាន់មិនបាន
ភេទនោះនឹងនាំប្រាណ    ទៅនរកដោយប្រាកដ ។
ដូច្នេះត្រូវអើពើ    តាំងចិត្តធ្វើឱ្យហ្មត់ចត់
ឱ្យត្រូវតាមបែបបទ    នៃធុរៈក្នុងសាសនា ។
បើធ្វើសមណធម៌    មិនបានល្អគ្រប់ប្រការ
កិលេសផងនានា    តែងចម្រើនដោយក្រៃលែង ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២ *(កាសែតទី ០៥A)*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវស្ត្រីពូកែច្រណែនម្នាក់ ទើបត្រាស់នូវព្រះគាថានេះថា

**អកតំ ទុក្កតំ សេយ្យោ បច្ឆា តប្បតិ ទុក្កតំ**
**កតញ្ច សុកតំ សេយ្យោ យំ កត្វា នានុតប្បតិ។**

អំពើអាក្រក់ ដែលបុគ្គលមិនធ្វើ ប្រសើរជាង (ព្រោះថា) អំពើអាក្រក់ រមែងធ្វើឱ្យក្ដៅក្រហាយក្នុងកាលខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្ដៅក្រហាយក្រោយ អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គលប្រសើរ ។

# បទភាគគតិ

អំពើអាក្រក់ ប្រៀបដូចភ្លើងភ្នក់ នាំក្តៅក្រហាយ
បុគ្គលមិនគួរ ធ្វើបាបទាំងឡាយ ដែលនាំចិត្តកាយ
ឱ្យស្តាយពេលក្រោយ ។
អំពើណាល្អ ធ្វើហើយត្រេកអរ ក្នុងចិត្តញ្វយៗ
គួរតែប្រព្រឹត្ត កុំបីថ្លោះធ្លោយ អំពើនោះហើយ
ឈ្មោះថាប្រសើរ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ៣ *(កាសែតទី ០៦A)*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុអាគន្តុកៈច្រើនរូប ទើបត្រាស់នូវព្រះគាថានេះថា

**នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ**
**ឯវំ គោបេថ អត្តានំ ខណោ មា វោ ឧបច្ចគា**
**ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា។**

នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយទាំងខាងក្នុង ទាំងខាងក្រៅ យ៉ាងណា អ្នកទាំងឡាយគួររក្សាខ្លួនយ៉ាងនោះ កុំឱ្យខណៈកន្លងអ្នកទាំងឡាយបានឡើយ ព្រោះថា ជនទាំងឡាយ ដែលឱ្យខណៈកន្លងហើយ រមែងសោកស្តាយ ក្នុងនរក មីរដេរដាស។

# កំណាព្យបទពាក្យ ៧

ព្រំដែននគរដែលក្សត្រា    គ្រប់គ្រងរក្សាបានដោយល្អ
ស្រុកទេសគង់វង្សមិនរឹកវរ    រុងរឿងបវរទាំងក្នុងក្រៅ ។
យ៉ាងណាវីរអ្នកទាំងឡាយអើយ    ចូរកុំកន្តើយត្រូវប្រដៅ
ទូន្មានឥន្ទ្រិយទាំងក្នុងក្រៅ    កុំឱ្យធ្លាក់ជ្រៅដោយតណ្ហា ។
ខណៈរស់នៅមិនយូរឡើយ    បើអ្នកព្រងើយពិតអសារ
គួរចេះប្រើប្រាស់ពេលវេលា    ត្រូវធ្វើការងារកុំទំនេរ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ៤ *( កាសែតទី ០៦B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវពួកនិគ្រន្ថ ទើបត្រាស់នូវព្រះគាថានេះថា

**អលជ្ជិតាយេ លជ្ជន្តិ លជ្ជិតាយេ ន លជ្ជរេ**
**មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។**
**អភយេ ភយទស្សិនោ ភយេ ច អភយទស្សិនោ**
**មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។**

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាស ក្នុងហេតុដែលគេមិនត្រូវខ្មាស រមែងមិនខ្មាសក្នុងហេតុដែលគេត្រូវខ្មាស សត្វនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលគេមិនត្រូវខ្លាច ថាជាហេតុដែលគេត្រូវខ្លាចផង យល់ឃើញក្នុងហេតុដែលគេត្រូវខ្លាច ថាជាហេតុដែលគេមិនត្រូវខ្លាចផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

~ ១០ ~

# បទព្រហ្មគីតិ

បុគ្គលអ្នកយល់ខុស　　សំគាល់ទោសថាជាគុណ
មិនជ្រះថ្លាក្នុងបុណ្យ　　សរសើរគុណកម្មលាមក ។
ខ្វាសអៀនសេចក្ដីល្អ　　ត្រេកសាទរកម្មអាក្រក់
តែងទៅកាន់នរក　　ឆេះក្នុងភ្នក់អវិចី ។
ជូនខ្លាចអំពើល្អ　　ហើយសាទរពួកធមិហីន៍
គតិអ្នកទាំងពីរ　　ពិតហីនាដូចតែគ្នា ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៥ *( កាសែតទី ០៧B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវពួកសាវ័កតិរ្ថិយទាំងឡាយ ទើបត្រាស់នូវព្រះគាថានេះថា

**អវជ្ជេ វជ្ជមតិនោ　　វជ្ជេ អវជ្ជទស្សិនោ**
**មិច្ឆាទិដ្ឋិសមាទានា　　សត្តា គច្ឆន្តិ ទុគ្គតឹ ។**
**វជ្ជញ្ច វជ្ជតោ ញត្វា　　អវជ្ជញ្ច អវជ្ជតោ**
**សម្មាទិដ្ឋិសមាទានា　　សត្តា គច្ឆន្តិ សុគ្គតឹ ។**

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញ ក្នុងហេតុដែលមានទោស

ថាជាហេតុឥតទោសផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់មានទោស ថាជារបស់មានទោសផង ដឹងរបស់មិនមានទោស ថាជារបស់មិនមានទោសផង សត្វទាំងនោះ តែងទៅកាន់សុគតិ ។

# បទពាក្យ ៧

មិច្ឆាទិដ្ឋិមានក្នុងអ្នកណា
អ្នកនោះយល់ថាទោសជាគុណ
ឃើញកម្មអាក្រក់ថាជាបុណ្យ
នេះហើយជាទុននៃអបាយ ។
ចំណែកបុគ្គលអ្នកយល់ត្រូវ
តែងដើរតាមផ្លូវអ្នកប្រាជ្ញប្រាយ
ស្គាល់ទោសដឹងគុណបានយ៉ាងងាយ
មានបរលោកនាយជាសុគតិ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៦[១] *(កាសែតទី 09A)*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងកោសម្ពី ទ្រង់ប្រារព្ធនូវរឿងរបស់ព្រះអង្គ ទើបត្រាស់នូវព្រះគាថានេះថា

**អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ**

**អតិវាក្យន្តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ។**

**ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ**

**ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យន្តិតិក្ខតិ ។**

**វរមស្សតរា ទន្តា អាជានីយា វ សិន្ធវា**

**កុញ្ជរា វ មហានាគា អត្តទន្តោ តតោ វរំ ។**

---

១-បើរាប់តាមលំដាប់ក្នុងនាគវគ្គ ត្រូវជា គាថា ទី ១

តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដំរីកាល អត់ទ្រាំចំពោះព្រួញដែលរបូតចេញអំពីធ្នូ ក្នុងសង្គ្រាម ដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។ ពួកជនតែងនាំវាហនៈ ដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងកាន់វាហនៈ ដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណាអត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅបានបទហើយរាប់ថាជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មានបានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

## បទពាក្យ ៧

ពួកជនទ្រុស្តសីលមានច្រើននាក់

តែងនិយាយពាក្យមិនគប្បី

គួរតែអត់ទ្រាំដូចដំរី

ក្នុងសង្គ្រាមជ័យស៊ូនឹងសរ ។

មិនគួរបិទមាត់អ្នកដទៃ

គួរលៃទូន្មានចិត្តឱ្យល្អ

ពាលស្អប់តែប្រាជ្ញតែងសាទរ

គ្រប់សេចក្តីល្អដែលយើងមាន ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ៧ *( កាសែតទី ១០A )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ដែលធ្លាប់ជាហ្មដំរី ទើបត្រាស់នូវព្រះគាថានេះថា

**ន ហិ ឯតេហិ យានេហិ គច្ឆេយ្យ អគតំ ទិសំ**

**យថាត្តនា សុទន្តេន ទន្តោ ទន្តេន គច្ឆតិ ។**

បុគ្គលទូន្មានខ្លួនបានបទហើយ ទូន្មានខ្លួនល្អហើយ ឈ្មោះថា ទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅគឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានទាំងឡាយនោះឡើយ ។

# កំណាព្យបទពាក្យ ៩

ព្រះនិព្វាន យានដទៃ ទៅមិនបាន
ព្រោះគ្មានខន្ធ គ្មានកងទុក្ខ រុកឆាឆៅ
ទោះយានដី យានអវកាស មិនអាចទៅ
ព្រោះជាផ្លូវ ទៅបានតែ អរិយៈ ។
បើអ្នកណា ភ្វារស្មារតី ទូន្មានខ្លួន
ឱ្យមាំមួន ផ្ទួនដើរតាម អរិយមគ្គ
មានបញ្ញា ឃើញតាមធមិ ដ៏ជាក់លាក់
អ្នកនោះជាក់ បានដល់ថ្នាក់ ព្រះនិព្វាន ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## **គាថាទី ៨**(*កាសែតទី ១១A*)

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវបុត្ររបស់ព្រាហ្មណ៍ចាស់ម្នាក់ ទើបត្រាស់នូវព្រះគាថានេះថា

**ធនបាលកោ នាម កុញ្ជរោ**
**កដុកប្បភេទនោ ទុន្និវារយោ**
**ពទ្ធោ កពឡំ ន ភុញ្ជតិ**
**សុមរតិ នាគវនស្ស កុញ្ជរោ។**

ដំរីឈ្មោះធនបាល ជាសត្វចុះប្រេង ក្សៀវក្លានាយហត្ថាចារ្យឃាត់បានដោយលំបាក បើនាយហត្ថាចារ្យ ចងភ្ជាប់ មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃខ្ទឹងដែលដំរីនោះធ្លាប់នៅ ។

# បទពាក្យ ៨

ដំរីធនបាលកាលត្រូវគេចាប់
យកមកប្រដាប់ដោយអលង្ការ
ទំនុកបម្រុងដោយភោជនាហារ
ដ៏ឆ្ងាញ់ពិសានៅក្នុងនគរ ។
ទោះគេឧបត្ថម្ភសមរម្យដល់ម្ល៉ោះ
ដំរីនាគនោះក៏មិនត្រេកអរ
តែងនឹកព្រៃខ្ទឹងជាទីគោចរ
រលឹកដល់ធមិចិញ្ចឹមមាតា ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ៩ *( កាសែតទី ១២B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះបាទបសេនទិកោសល ទើបត្រាស់នូវព្រះគាថានេះថា

**មិទ្ធី យទា ហោតិ មហគ្ឃសោ ច**
**និទ្ទាយិតា សម្បរិវត្តសាយី**
**មហាវរាហោវ និវាបបុដ្ឋោ**
**បុនប្បុនំ គព្ភមុបេតិ មន្ទោ ។**

កាលណា បុគ្គលអ្នកមានសេចក្តីងោកងុយផង អ្នកបរិភោគភោជនមានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះនឿលផង ដូចជ្រូកស្រុក ដែលបុគ្គលចិញ្ចឹម ដោយសូករភត្ត កាលនោះបុគ្គលនោះ ជាមនុស្សខ្លៅ រមែងចូលទៅកាន់គភ៌រឿយ ៗ ។

# បទព្រហ្មគីតិ

បុគ្គលងោកងុយផង　　ស៊ីច្រើនផងហួសប្រមាណ
ដេកលក់មិនដឹងប្រាណ　　ដេកប្រៀបបាននិងជ្រូកស្រុក ។
ជ្រូកស្រុកគេចិញ្ចឹម　　ដេកសង្ឃឹមតែបាយស្នូក
ពេលឃ្លានស្រែកងូកៗ　　ឆ្ងាញ់បាយស្នូកមិនដឹងប្រាណ ។
លុះខ្លួនធំពេញវ័យ　　ម្ចាស់លកលៃលក់មិនខាន
ជ្រូកឥតទទួលបាន　　ក្សាន្តសុខពិតព្រោះដេកស៊ី ។
អ្នកណាត្រាប់សត្វជ្រូក　　ខ្ជិលងុយងោកឥតសម្តី
តែងចូលកាន់ភពថ្មី　　ពិតគ្មានថ្ងៃរួចចាកទុក្ខ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១០ *( កាសែតទី ១៣B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវសានុសាមណេរ ទើបត្រាស់នូវព្រះគាថានេះថា

**ឥទំ បុរេ ចិត្តមចារិ ចារិកំ**

**យេនិច្ឆកំ យត្ថកាមំ យថាសុខំ**

**តទជ្ជហំ និគ្គហេស្សាមិ យោនិសោ**

**ហត្ថិប្បភិន្នំ វិយ អំកុសគ្គហោ ។**

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមអាការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្តីសប្បាយក្នុងថ្ងៃនេះ អញនឹងសង្កត់សង្កិនចិត្តនោះ ដោយឧបាយ ដូចហ្មដំរីកាន់កង្វេរសង្កត់សង្កិនដំរីចុះប្រេង ដូច្នោះដែរ ។

~ ២៤ ~

# កំណាព្យបទពាក្យ ៧

ធម្មជាតិដែលមានឈ្មោះថាចិត្ត

តែងតែរិះគិតជាធម្មតា

ត្រាច់ចរតាមតែខ្លួនប្រាថ្នា

មិនងាយអ្នកណាទប់ស្កាត់បាន ។

មិនត្រូវបណ្តោយតាមគំនិត

ត្រូវទូន្មានចិត្តកុំខកខាន

ដូចហ្មដំរីដ៏ក្លាហាន

ទូន្មានដំរីដែលចុះប្រេង ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ១១ *( កាសែតទី ១៥A )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវដំរីឈ្មោះបាវេរកៈ របស់ព្រះបាទបសេនទិកោសល ទើបត្រាស់នូវព្រះគាថានេះថា

**អប្បមាទរតា ហោថ សចិត្តមនុរក្ខថ**
**ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។**

អ្នកទាំងឡាយ ចូរត្រេកអរ ក្នុងសេចក្ដីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួន ចូររើខ្លួនចេញចាកភក់គឺកិលេស ដែលឆ្លងបានដោយកម្រ ដូចដំរីដែលជាប់នៅក្នុងភក់ រើខ្លួនឱ្យរួចបាន ។

# បទព្រហ្មគីតិ

បុគ្គលគួរត្រេកអរ　　នៅក្នុងធម៌មិនប្រមាទ
ខាត់ចិត្តឱ្យបានស្អាត　　សង្វាតធ្វើសេចក្តីល្អ ។
គួររើខ្លួនចាកភក់　　ដ៏អាក្រក់សែនរឹករវរ
ពោលគឺកិលេសធម៌　　កុំត្រេកអរធម៌ហីនា ។
ដូចដំរីជាប់នៅ　　ក្នុងភក់ជ្រៅខែវស្សា
ខំរើដោយហានក្លា　　ដោះអាត្មាចាកភក់បាន ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ១២ *( កាសែតទី ១៥B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងព្រៃឈ្មោះរក្ខិតៈ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ទើបត្រាស់នូវព្រះគាថានេះថា

សចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតិមា ។
នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

**ឯកស្ស ចរិតំ សេយ្យោ**

**នត្ថិ ពាលេ សហាយតា**

**ឯកោ ចរេ ន ច បាបានិ កយិរា**

**អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។**

បើបុគ្គលបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធមិជាគ្រឿងនៅញ៉ាំងប្រយោជន៍ឱ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតីគ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនិងសំឡាញ់នោះឯង ។ បើស្វែងរកមិនបានសំឡាញ់ ដែលមានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធមិ ជាគ្រឿងញ៉ាំង

ប្រយោជន៍ឱ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ ដែលទ្រង់ឈ្នះហើយស្តេចទៅតែឯកអង្គ ពុំនោះសោតដូចដំរីឈ្មោះមាតង្គៈ ដែលលះហ្វូងត្រាច់ទៅតែឯកឯងក្នុងព្រៃដូច្នោះដែរ ។

ការត្រាច់ទៅរបស់បុគ្គលឯកឯង ជាគុណជាតិប្រសើរផុត (ព្រោះថា) សហាយតាគុណ រមែងមិនមានក្នុងជនពាលឡើយ បុគ្គលនោះគប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផងមិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះ-មាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូងត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

# កំណាព្យបទព្រហ្មគីតិ

បើបានជួបមិត្តល្អស្មោះស
　　　　　　គួរតែត្រេកអររាប់អានទៅ
មិត្តល្អតែងនាំទៅរកផ្លូវ
　　　　　　សុចរិតត្រឹមត្រូវក្នុងជីវិត ។
បើស្វែងរកមិត្តល្អមិនបាន
　　　　　　គួរប្រយ័ត្នប្រាណកុំដើរជិត
ជនពាលអប្បល័ក្ខណ៍គ្មានសុចរិត
　　　　　　ក្រែងនាំជីវិតងងឹតសូន្យ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ១៣ *( កាសែតទី ១៦ B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងកុដិ ដែលតាំងនៅក្បែរព្រៃហិមពាន្ត ទ្រង់ប្រារព្ធនូវមារ ទើបត្រាស់នូវព្រះគាថានេះថា

អត្ថម្ហិ ជាតម្ហិ សុខា សហាយា
តុដ្ឋី សុខា យា ឥតរីតរេន
បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ
សព្វស្ស ទុក្ខស្ស សុខំ បហានំ ។

សុខា មត្តេយ្យតា លោកេ អថោ បេត្តេយ្យតា សុខា
សុខា សាមញ្ញតា លោកេ អថោ ព្រហ្មញ្ញតា សុខា។
សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា
សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ។

កាលបើសេចក្តីត្រូវការ កើតឡើងហើយ សំឡាញ់ទាំងឡាយនាំសេចក្តីសុខមកឱ្យ សេចក្តីត្រេកអរដោយបច្ច័យ តាមមានតាមបាន ជាហេតុនាំសេចក្តីសុខមកឱ្យ បុណ្យនាំសេចក្តីសុខមកឱ្យក្នុងកាលទៀបក្ស័យជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឱ្យ ។

សេចក្តីប្រតិបត្តិល្អក្នុងមាតា នាំសេចក្តីសុខមកឱ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អក្នុងបិតា នាំសេចក្តីសុខមកឱ្យ សេចក្តីប្រតិបត្តិល្អក្នុងសមណៈ នាំសេចក្តីសុខមកឱ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អក្នុងព្រាហ្មណ៍ នាំសេចក្តីសុខមកឱ្យ សីលនាំសេចក្តីសុខមកឱ្យ ដរាបដល់ចាស់ សទ្ធាដែលបុគ្គលតម្កល់ស៊ប់ហើយ នាំសេចក្តីសុខមកឱ្យ ការបាន

ប្រាជ្ញានាំសេចក្តីសុខមកឱ្យ ការមិនធ្វើបាប ទាំងឡាយនាំសេចក្តីសុខមកឱ្យ ។

# បទពាក្យ ៨

បដិបត្តិមាតាបិតាដោយល្អ

ជាសប្បុរសធម៌ដ៏ល្អពិសិដ្ឋ

គោរពសមណៈឬមួយបព្វជិត

នោះពិតជាធម៌នាំមកនូវសុខ ។

សីលដែលបុគ្គលរក្សាខ្ជាប់ខ្ជួន

ពិតជានាំខ្លួនឱ្យរួចចាកទុក្ខ

សទ្ធាដែលជឿត្រឹមត្រូវគ្រប់មុខ

នឹងបានក្ដីសុខមិនខកចិន្ដា ។

ការបានប្រាជ្ញានាំមកនូវសុខ

ព្រោះឃើញកងទុក្ខរួចចាកមោហា

# ការមិនធ្វើបាបសព្វគ្រប់ប្រការ

# ពិតបានសុខាអស់ក្តីសៅហ្មង ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១៥[1] *(កាសែតទី ១៧B)*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវត្រីឈ្មោះកបិលៈ ទើបត្រាស់នូវព្រះគាថានេះថា

**មនុជស្ស បមត្តចារិនោ**

**តណ្ហា វឌ្ឍតិ មាលុវា វិយ**

**សោ បលវតី ហុរាហុរំ**

**ផលមិច្ឆំវ វនស្មឹ វានរោ ។**

**យំ ឯសា សហតី ជម្មី តណ្ហា លោកេ វិសត្តិកា**

---

១-បើរាប់តាមលំដាប់ក្នុងតណ្ហាវគ្គ ត្រូវជាគាថា ទី ១

សោកា តស្ស បវឌ្ឍន្តិ អភិវឌ្ឍំវ វីរណំ ។
យោ វេ តំ សហតី ជម្មឹ តណ្ហំ លោកេ ទុរច្ចយំ
សោកា តម្ហា បបតន្តិ ឧទពិន្ទុវ បោក្ខរា ។
តំ វោ វទាមិ ភទ្ទំ វោ យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខណថ ឧសីរត្ថោវ វីរណំ
មា វោ នឡំ វ សោតោវ មារោ ភញ្ជិ បុនប្បុនំ ។

តណ្ហា តែងចម្រើនដល់មនុស្សអ្នកមានការប្រព្រឹត្តដោយសេចក្ដីប្រមាទជាប្រក្រតី ដូចវល្លិរួបរឹតដើមឈើហើយ ចម្រើនឡើង បុគ្គលនោះ តែងស្ទុះទៅកាន់ភពតូចភពធំ ដូចស្វា កាលប្រាថ្នាផ្លែឈើលោតទៅក្នុងព្រៃ ដូច្នោះដែរ ។

តណ្ហាន៎ុះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេង ៗ ក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្ដីសោកស្ដាយ តែងចម្រើនឡើង ដល់បុគ្គលនោះ ដូចស្មៅវរណ្ដាស ដែលត្រូវភ្លៀងធ្លាក់ចុះ ជញ្រាំហើយ ពន្លកលូតលេចឡើង ដូច្នោះដែរ ។

ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមក ក្នុងលោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្ដីសោកស្ដាយ តែងធ្លាក់ចេញចាកជននោះឯង ដូចដំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូក ដូច្នោះដែរ ។

ព្រោះហេតុនោះបានជាតថាគតប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមកប្រជុំគ្នាក្នុងទីនេះ សេចក្តីចម្រើនចូរមានដល់អ្នកទាំងឡាយទាំងប៉ុណ្ណោះចុះ អ្នកទាំងឡាយចូររំលើងឫសតណ្ហាចោលចេញ ដូចបុគ្គលត្រូវការដោយស្បូវភ្លាំង គាស់ស្បូវរណ្តាសចោលចេញដូច្នោះ ។ មារកុំរុករានអ្នកទាំងឡាយរឿយ ៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុសដូច្នោះឡើយ ។

# បទពាក្យ ៧

តណ្ហាជាធមិអកុសល

តែងកើតមានដល់អ្នកប្រមាទ

ប្រៀបដូចជាវល្លិតែងរុំព័ទ្ធ

ដើមរុក្ខជាតិឱ្យក្ស័យប្រាណ ។

បុគ្គលនោះឯងតែងស្ទុះទៅ

ឥតមានគោលដៅក្នុងភពឋាន

ដូចស្វាលោតឥតសម្រាកប្រាណ

ប្រាថ្នាចង់បានផ្លែឈើព្រៃ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១៥ *( កាសែតទី ១៨B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវកូនជ្រូកញី ទើបត្រាស់នូវព្រះគាថានេះថា

យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ
ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ
និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។
យស្ស ឆត្តឹសតី សោតា មនាបស្សវនា ភុសា
មហា វហន្តិ ទុទ្ទិដ្ឋឹ សង្កប្បា រាគនិស្សិតា ។

សវន្តិ សព្វធី សោតា   លតា ឧព្ភិជ្ជ តិដ្ឋតិ
តញ្ច ទិស្វា លតំ ជាតំ   មូលំ បញ្ញាយ ឆិន្ទថ ។

សរិតានិ សិនេហិតានិ ច
សោមនស្សានិ ភវន្តិ ជន្តុនោ
តេ សាតសិតា សុខេសិនោ
តេ វេ ជាតិជរូបគា នរា ។

តសិណាយ បុរក្ខតា បជា
បរិសប្បន្តិ សសោវ ពាធិតោ
សញ្ញោជនសង្គសត្តា
ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។

**តសិណាយ បុរក្ខតា បជា**

**បរិសប្បន្តិ សសោវ ពាធិតោ**

**តស្មា តសិណំ វិនោទយេ**

**ភិក្ខុ អាកង្ខំ វិរាគមត្តនោ ។**

កាលបើឫសឈើ មិនមានសេចក្ដីអន្តរាយ នៅមាំមួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះឡើងទៀតបាន មានឧបមាដូចម្ដេចមិញ កាលបើតណ្ហានុស័យ បុគ្គលកម្ចាត់មិនទាន់បានហើយ ទុក្ខ (មានជាតិទុក្ខជាដើម) នេះ ក៏តែងកើតរឿយ ៗ មានឧបមេយ្យ ដូច្នោះឯង ។

ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅក្នុងអារម្មណ៍ ជាទីគាប់ចិត្ត ជាធម្មជាតិក្លៀវក្លា មានដល់បុគ្គលណា តម្រិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ តែងនាំនូវទិដ្ឋិអាក្រក់របស់បុគ្គលនោះ ។

ខ្សែតណ្ហាទាំងឡាយ តែងហូរទៅក្នុងអារម្មណ៍ទាំងពួង ដូចជាវល្លិដែលបែកខ្នែងឡើង តាំងនៅដូច្នោះ បើអ្នកទាំងឡាយឃើញតណ្ហា ដូចជាវល្លិនោះ កើតឡើងហើយ ចូរកាត់ឫសចោលចេញ ដោយកាំបិតគឺបញ្ញា ។

សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្ដីស្រឡាញ់ផង រមែងមានដល់សត្វ ពួកសត្វនោះ ជាអ្នកអាស្រ័យនូវសេចក្ដីរីករាយ អ្នកស្វែងរកសេចក្ដីសុខ នរជនទាំង-ឡាយនោះឯង តែងឈមទៅរកជាតិនិងជរា ។

ពួកសត្វដែលតណ្ហា ជាទីញ៉ាំងសត្វឱ្យតក់ស្លុតក្រុងទុកហើយ តែងរន្ធត់ដូចទន្សាយដែលព្រានទាក់បានហើយដូច្នោះ ពួកសត្វដែលជាប់ក្នុងសំយោជនៈនិងសង្គធមិ (ធមិជាគ្រឿងជំពាក់) តែងដល់នូវសេចក្ដីទុក្ខរឿយ ៗ អស់កាលអង្វែង។

ពួកសត្វដែលតណ្ហា ជាទីញុំាងសត្វឱ្យតក់ស្លុតក្រុងទុកហើយ តែងរន្ធត់ដូចទន្សាយ ដែលនាយព្រានទាក់បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌មិនជាគ្រឿងប្រាសចាករាគៈ ដើម្បីខ្លួន គប្បីបន្ទោបង់តណ្ហា ដែលជាគ្រឿងតក់ស្លុតចោលចេញ ។

# បទពាក្យ ៧

ចង់រួចចាកទុក្ខក្នុងសង្សារ
ត្រូវកាត់តណ្ហាជាឫសគល់
តណ្ហាជាមេនាំឱ្យដល់
កើតស្លាប់វិលវល់ក្នុងសង្សារ ។
ប្រៀបដូចជាដើមរុក្ខជាតិ
តែងដុះតទៀតព្រោះមូលា
បើកាប់រំលើងឫសឱ្យផ្ងារ
ជាតិជារុក្ខាដុះលែងបាន ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១៦ *( កាសែតទី ១៩B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវវិព្ភន្តកភិក្ខុ ទើបត្រាស់នូវព្រះគាថានេះថា

**យោ និព្វនដ្ឋោ វនាធិមុត្តោ**

**វនមុត្តោ វនមេវ ធាវតិ**

**តំ បុគ្គលមេវ បស្សថ**

**មុត្តោ ពន្ធនមេវ ធាវតិ ។**

បុគ្គលណា មិនមានអាល័យ ក្នុងគិហិភាព ដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តចុះស៊ប់ក្នុងព្រៃគឺតបធម៌ ជាអ្នករួចស្រឡះចាកព្រៃគឺតណ្ហា ហើយស្ទុះទៅរកព្រៃគឺតណ្ហាវិញ អ្នកទាំងឡាយចូរមើល

បុគ្គលនោះឯង បុគ្គលនោះរួចចាកចំណងគឺឃរាវាស ហើយ ស្ទុះទៅរកចំណងគឺឃរាវាសវិញ ។

# បនភាគគតិ

មានចិត្តកាត់លះ ភាពឃរាវាស ចូលបព្វជ្ជា
ជាដំណើរល្អ ដែលព្រះភគវា ទ្រង់សរសើរថា
អ្នករួចចំណង ។
តែចិត្តមិនស្ងប់ បែរជាត្រឡប់ ប្រព្រឹត្តឆ្គាំឆ្គង
លាភេទឧត្តម កាន់ភេទសៅហ្មង វិលចូលចំណង
ព្រៃគឺតណ្ហា ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ១៧ *( កាសែតទី ២០A )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវពន្ធនាគារ ទើបត្រាស់ នូវព្រះគាថានេះថា

**ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា**

**យទាយសំ ទារុជំ បព្វជញ្ច ។**

**សារត្តរត្តា មណិកុណ្ឌលេសុ**

**បុត្តេសុ ទារេសុ ច យា អបេក្ខា**

**ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា**

**ឱហារិនំ សិថិលំ ទុប្បមុញ្ចំ**

## ឯតំបិ ឆេត្វាន បរិព្វជន្តិ

## អនបេក្ខិនោ កាមសុខំ បហាយ ។

ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅយាប្លងក្តី អ្នកប្រាជ្ញមិនហៅចំណងនោះ ថាជាចំណងមាំមួនឡើយ ។

ពួកជនណា ត្រេកអរក្រៃពេក ក្នុងកែវមណីនិងកុណ្ឌលទាំងឡាយក្តី សេចក្តីអាឡោះអាល័យកូននិងប្រពន្ធទាំងឡាយក្តី អ្នកប្រាជ្ញទាំងឡាយ ហៅសេចក្តីត្រេកអរ និងសេចក្តីអាឡោះអាល័យនោះ

ថាជាចំណងមាំមួន ជាចំណងនាំចុះ (ទាញសត្វទម្លាក់ទៅក្នុងអបាយ) ជាចំណងធូរទេ ប៉ុន្តែសត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញទាំងឡាយកាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់កាមសុខ ហើយចេញបួស ។

# បទព្រហ្មគីតិ

ចំណងដែកឬឈើ ឬធ្វើពីស្មៅយាប្លង
មិនចាត់ជាចំណង ដ៏មាំមួនបំផុតឡើយ ។
តម្រេកក្នុងភរិយា ឬទ្រព្យាបុត្តត្រើនត្រើយ
ការត្រេកអរនោះហើយ ជាចំណងមាំអស្ចារ្យ
អ្នកប្រាជ្ញបញ្ញាវៃ លះអាល័យក្នុងកាមា
តែងចេញចាកគេហា សាងបព្វជ្ជាស្រាយចំណង ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ១៨ *( កាសែតទី ២០B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវព្រះនាងខេមាថេរី ទើបត្រាស់នូវព្រះគាថានេះថា

**យេ រាគរត្តានុបតន្តិ សោតំ**

**សយំ កតំ មក្កដកោវ ជាលំ**

**ឯតម្បិ ឆេត្វាន វជន្តិ ធីរា**

**អនបេក្ខិនោ សព្វទុក្ខំ បហាយ ។**

ពួកជនណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់

ខ្លួនចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះទុក្ខទាំងពួង ចេញទៅ។

# បទពាក្យ ៨

ជនណាត្រេកអរព្រោះតែរាគៈ
តែងតែធ្លាក់ចុះកាន់ខ្សែតណ្ហា
ប្រៀបដូចពីងពាងទម្លាក់អត្តា
ចូលសម្បុកវាជាប្រក្រតី ។
អ្នកប្រាជ្ញតែងកាត់ខ្សែតណ្ហានោះ
ជាមេទុក្ខទោសក្នុងភពទាំងបី
ជាអ្នកមិនមានសេចក្ដីអាល័យ
រួចចាកទុក្ខភ័យក្នុងសង្សារវដ្ដ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ១៩ *(កាសែតទី ២២A)*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវបុត្រសេដ្ឋីឈ្មោះឧគ្គសេន ទើបត្រាស់នូវព្រះគាថានេះថា

**មុញ្ច បុរេ មុញ្ច បច្ឆតោ**

**មជ្ឈេ មុញ្ច ភវស្ស បារគូ**

**សព្វត្ថ វិមុត្តមានសោ**

**ន បុន ជាតិជរំ ឧបេហិសិ ។**

អ្នកចូរដោះ (សេចក្តីអាល័យ) ក្នុងកាលមុនចេញ ចូរដោះ (សេចក្តីអាល័យ) ក្នុងខាងក្រោយចេញ

ចូរដោះ (សេចក្ដីអាល័យ) ក្នុងកាលជាកណ្ដាលចេញ (កាលបើធ្វើយ៉ាងនេះ) អ្នកនឹងដល់ត្រើយនៃភព នឹងមានចិត្តរួចស្រឡះ ចាកសង្ខតធម៌ទាំងពួង មិនត្រូវទៅកាន់ជាតិនិងជរាទៀតឡើយ ។

# បទពាក្យ ៨

មិនគួរជាប់ចិត្តនឹងអតីតកាល
កុំត្រេកត្រអាលនឹងអនាគត
ទោះបច្ចុប្បន្នកំពុងប្រាកដ
មិនគួរសន្ទុតថាទៀងទាត់ឡើយ ។
កាលណាបើអ្នកលះក្តីអាល័យ
ក្នុងកាលទាំងបីចិត្តអ្នកនឹងស្បើយ
ជរាព្យាធិនឹងលែងមានហើយ
ព្រោះបានដល់ត្រើយនៃសង្សារវដ្ត ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២០ *( កាសែតទី ២៣B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវចូឡធនុគ្គហបណ្ឌិត ទើបត្រាស់នូវព្រះគាថានេះថា

វិតក្កមថិតស្ស ជន្តុនោ
តិព្វរាគស្ស សុភានុបស្សិនោ
ភិយ្យោ តណ្ហា បវឌ្ឍតិ
ឯស ខោ ទឡ្ហំ ករោតិពន្ធនំ ។
វិតក្កូបសមេ ច យោ រតោ

**អសុភំ ភាវយតី សទា សតោ**

**ឯស ខោ វ្យន្តិកាហតិ**

**ឯសច្ឆេច្ឆតិ មារពន្ធនំ ។**

តណ្ហា រមែងចម្រើនក្រៃលែង ដល់ជនដែលវិតក្កៈញាំញី មានតម្រេកក្លៀវក្លា យល់ឃើញអារម្មណ៍ថាល្អ បុគ្គលនោះឯងឈ្មោះថាធ្វើចំណងឱ្យមាំមួន ។ លុះតែបុគ្គលណា ត្រេកអរក្នុងអសុភជ្ឈានដែលជាហេតុឱ្យស្ងប់រម្ងាប់នូវវិតក្កៈ មានស្មារតីសព្វកាល តែងចម្រើនអសុភជ្ឈាន បុគ្គលនោះឯង នឹងធ្វើតណ្ហាឱ្យអស់ទៅបាន បុគ្គលនោះឯង ទើបឈ្មោះថាកាត់ចំណងមារបាន ។

# បទព្រហ្មគីតិ

តណ្ហាតែងកើតមាន ដល់សន្ដានពួកជនណា
មានចិត្តអន្ទះសា ត្រិះរិះក្នុងកាមារម្មណ៍ ។
ឃើញអារម្មណ៍ធម្មតា ត្រិះរិះថាស្អាតឧត្ដម
ខ្សែតូចទៅជាធំ កាន់តែមាំស្រាយមិនបាន ។
លុះតែចម្រើនធម៌ ត្រេកអរក្នុងអសុភជ្ឈាន
តែងកាត់តណ្ហាបាន ស្ងប់សន្ដានរួចចាកមារ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២១ *( កាសែតទី ២៤B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវមារ ទើបត្រាស់នូវព្រះគាថានេះថា

**និដ្ឋង្គតោ អសន្តាសី វីតតណ្ហោ អនង្គណោ**
**អច្ឆិន្ទិ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។**
**វីតតណ្ហោ អនាទានោ និរុត្តិបទកោវិទោ**
**អក្ខរានំ សន្និបាតំ ជញ្ញា បុព្វាបរានិ ច**
**ស វេ អន្តិមសារីរោ មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ។**

បុគ្គលណា ដល់សេចក្តីសម្រេចគឺអរហត្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេស

ដូចទីទួល បានកាត់កួនសរគឺកិលេស ជាហេតុញ៉ាំង សត្វឱ្យទៅកាន់ភពបានហើយ កាយដែលឆ្អឹង ៣០០ កំណាត់ ផ្គុំគ្នាហើយនេះ របស់បុគ្គលនោះ ឈ្មោះថា តាំងនៅក្នុងទីបំផុត ។

បុគ្គលណា មិនមានតណ្ហា មិនមានសេចក្ដី ប្រកាន់មាំ ជាអ្នកឈ្លាសក្នុងនិរុត្តិ (វាចាជាគ្រឿង សម្ដែងចេញ) និងបទដ៏សេស ដឹងច្បាស់នូវប្រជុំនៃ អក្ខរៈទាំងឡាយផង នូវខាងដើមនិងខាងចុង នៃអក្ខរៈ ទាំងឡាយផង បុគ្គលនោះឯង តថាគតហៅថាអ្នក មានសរីរៈឋិតនៅ ក្នុងទីបំផុត មានបញ្ញាច្រើន ជាមហា បុរស ។

# បទពាក្យ ៧

បុគ្គលណាមិនមានតណ្ហា ចិន្តាមិនគិតប្រកាន់មាំ
ឈ្លាសក្នុងនិរុត្តិខ្ពស់ឧត្តម ដឹងច្បាស់ប្រជុំអក្ខរា ។
បុគ្គលនោះឯងតថាគត សន្មតថាអ្នកមានបញ្ញា
មានសរីរៈផុតសង្សារ ប្រាកដនាមថាមហាបុរស ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២២ *( កាសែតទី ២៥B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវឧបកាជីវក ទើបត្រាស់នូវព្រះគាថានេះថា

**សព្វាភិភូ សព្វវិទូហមស្មិ**

**សព្វេសុ ធម្មេសុ អនូបលិត្តោ**

**សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ**

**សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។**

តថាគតជាអ្នកគ្របសង្កត់តេភូមិកធម៌ទាំងអស់ ដឹងច្បាស់ចតុព្ភូមិកធម៌ទាំងអស់ មានចិត្តមិនបានជាប់នៅក្នុងតេភូមិកធម៌ទាំងអស់ លះបង់តេភូមិកធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា បើតថាគត

ត្រាស់ដឹងធម៌ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណាជាគ្រូអាចារ្យទៀត ។

# បទព្រហ្មគីតិ

សម្មាសម្ពុទ្ធោ ប្រាកដធ្លោព្រះនាមល្បី
ចំពោះព្រះជិនស្រី បន្ទាប់ពីត្រាស់ដឹងជាក់ ។
ត្រាស់ដឹងដោយខ្លួនឯង ធម៌ក្រៃលែងគឺសច្ចៈ
ទ្រង់ជ្រាបធម៌គ្រប់ថ្នាក់ គ្មានអ្វីលាក់បាំងទ្រង់បាន ។
ទ្រង់លះអស់តណ្ហា គមនាទៅព្រះនិព្វាន
ដូច្នេះព្រះទ្រង់ញាណ មិនបាច់មានគ្រូទៀតឡើយ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២៣ *( កាសែតទី ២៦A )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវសក្កទេវរាជ ទើបត្រាស់នូវព្រះគាថានេះថា

**សព្វទានំ ធម្មទានំ ជិនាតិ**

**សព្វរសំ ធម្មរសោ ជិនាតិ**

**សព្វរតឹ ធម្មរតិ ជិនាតិ**

**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។**

ធម្មទានឈ្នះអាមិសទានទាំងពួង ធម្មរសឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហា ឈ្នះទុក្ខទាំងពួង ។

# បទពាក្យ ៧

ធម្មទានជាទានដ៏ប្រសើរ

គ្មានអ្វីប្រៀបស្មើក្នុងលោកា

ឈ្នះអាមិសទានផងនានា

សត្វមានបញ្ញាព្រោះធម្មទាន ។

រីរសនៃធម៌ព្រះភគវា

ឈ្នះអស់រសាគ្រប់សណ្ឋាន

ព្រោះអ្នកក្រេបផឹកតែងតែបាន

សុខស្ងប់សន្ដានអស់កង្វល់ ។

រីការត្រេកអរក្នុងព្រះធម៌

ឈ្នះការត្រេកអរសព្វសកល

ព្រោះអ្នកជួបហើយរមែងដល់

ចាកក្តីកង្វល់ក្នុងសន្តាន ។

ឯការអស់ទៅនៃតណ្ហា

ឈ្មោះអស់ទុក្ខាក្នុងភពឋាន

អស់ខន្ធអស់ទុក្ខរុករំខាន

សុខក្នុងនិព្វានគ្មានត្រឡប់ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៤ *(កាសែតទី ២៧A)*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវសេដ្ឋីអ្នកមិនមានបុត្រ ទើបត្រាស់នូវព្រះគាថានេះថា

**ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**

**ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។**

ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញា ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយគឺព្រះនិព្វានទេ ឯបុគ្គលអប្បប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងភោគៈ ។

# បទពាក្យ ៧

ភោគៈទាំងឡាយដែលកើតមាន
ប្រៀបបាននឹងអ្នកបម្រើល្អ
បើមានទ្រព្យហើយរស់ខ្វះធម៌
ជីវិតរីកវរព្រោះតែទ្រព្យ ។
ចំពោះបុគ្គលមានប្រាជ្ញា
ចាត់ថាជាមនុស្សរស់មានភ័ព្វ
លោកមិនវង្វេងព្រោះតែទ្រព្យ
តែងរួចចាកភពដល់និព្វាន ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២៥ *( កាសែតទី ២៨B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅលើបណ្ឌុកម្ពលសិលា ទ្រង់ប្រារព្ធនូវអង្កុរទេវបុត្រ ទើបត្រាស់នូវព្រះគាថានេះថា

**តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា**
**តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។**
**តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា**
**តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។**
**តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា**
**តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ ។**
**តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា**
**តស្មា ហិ វិគតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។**

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយ ដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្តីប្រាថ្នាជាទោស ព្រោះ

ហេតុនោះ ទានដែលបុគ្គលឱ្យហើយ ដល់អ្នកមានសេចក្តីច្រណែនអស់ហើយ រមែងជាទានមានផលច្រើន ។

## បទពាក្យ ៧

ស្រែដែលមិនល្អព្រោះមានស្មៅ
ជាទោសឆាឆៅស្រូវទាំងឡាយ
ធ្វើឱ្យស្រូវត្រូវអន្តរាយ
មិនងាយឱ្យផលតាមប្រាថ្នា ។
រីឯសត្វលោកក៏ដូច្នោះ
មានទោសព្រោះតែមានមោហា
លោភៈទោសៈនិងឥស្សា
ធ្វើឱ្យចិន្តាមិនបរិសុទ្ធ ។
ទានដែលគេឱ្យបុគ្គលនោះ
បើទោះជាឱ្យច្រើនបំផុត

ជាទានមិនល្អយ៉ាងប្រាកដ

ព្រោះខ្សត់ផលាអានិសង្ស ។

ឯការឱ្យដល់បុគ្គលណា

អ្នកមានចិន្តាស្អាតផូរផង់

ជាទានសម្បូរអានិសង្ស

ព្រោះបានឱ្យត្រង់បុគ្គលល្អ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៦[១] *( កាសែតទី ២៩B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុ ៥ រូប ទើបត្រាស់នូវព្រះគាថានេះថា

**ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ**
**ឃានេន សំវរោ សាធុ សាធុ ជិវ្ហាយ សំវរោ ។**
**កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ**
**មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ**
**សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។**

---

១-បើរាប់តាមលំដាប់ក្នុងភិក្ខុវគ្គ ត្រូវជាគាថា ទី ១

ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

# បទពាក្យ ៨

ភិក្ខុគួរតែសង្រួមឥន្ទ្រីយ៍
ឱ្យល្អប្រពៃមិនឱ្យរោយរាយ
ថែភ្នែកត្រចៀកច្រមុះទាំងឡាយ
ទាំងអណ្ដាតកាយចិត្តនិងវាចា ។

ភិក្ខុអ្នកសង្រួមទ្វារទាំងអស់
នឹងរួចចាកគ្រោះនៅក្នុងសង្សារ
ព្រោះឈប់នៅក្នុងអំណាចតណ្ហា
មាននិព្វានជាត្រើយសុខក្សេមក្សាន្ត ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៧ *( កាសែតទី ៣០ B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុអ្នកសម្លាប់ហង្សមួយរូប ទើបត្រាស់នូវព្រះគាថានេះថា

**ហត្ថសញ្ញតោ បាទសញ្ញតោ**
**វាចាយ សញ្ញតោ សញ្ញតត្តមោ**
**អជ្ឈត្តរតោ សមាហិតោ**
**ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។**

ជនណា សង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋានដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយហៅជននោះថា ភិក្ខុ ។

# បទពាក្យ ៧

ជនណាសង្រួមជើងនិងដៃ
　　　　មានឫកពាថ្លៃសម្ដីល្អ
សង្រួមអត្តភាពចិត្តស្មោះសរ
　　　　ត្រេកអរចម្រើនព្រះកម្មដ្ឋាន ។
ជាអ្នកមានចិត្តតម្កល់មាំ
　　　　សម្ងំតែឯងយ៉ាងសុខសាន្ត
ត្រេកអរក្នុងធម៌ស្ងប់សន្ដាន
　　　　បណ្ឌិតហៅបានថាភិក្ខុ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៨ *( កាសែតទី ៣១B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុឈ្មោះកោកាលិកៈ ទើបត្រាស់នូវព្រះគាថានេះថា

**យោ មុខសញ្ញតោ ភិក្ខុ មន្តភាណី អនុទ្ធតោ**
**អត្ថំ ធម្មញ្ច ទីបេតិ មធុរំ តស្ស ភាសិតំ ។**

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយសម្តែងអត្ថផង ធម៌ផងបាន ភាសិតរបស់ភិក្ខុនោះទើបឈ្មោះថាពីរោះ ។

# បទពាក្យ ៨

រីភិក្ខុណាអ្នកសង្រួមមាត់
មានបែបមានបទពោលដោយបញ្ញា
មិនរាយមាយចិត្តសម្បូរប្រាជ្ញា
ដឹងច្បាស់ធម្មាទាំងអត្ថនិងធម៌ ។
រីសុភាសិតនៃភិក្ខុនោះ
សម្តេចទ្រង់យសតែងតែសាទរ
ព្រោះជនអ្នកស្តាប់រមែងត្រេកអរ
ពីរោះខ្លឹមធម៌មានន័យទូលាយ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៩ *( កាសែតទី ៣៣A )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះធម្មារាមត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ**

**ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ។**

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយ ៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

# បទព្រហ្មគីតិ

ភិក្ខុមានសទ្ធា អ្នកជ្រះថ្លាក្នុងព្រះធម៌
ពិចារណាធម៌ រលឹកធម៌ជារឿយៗ ។
ជាអ្នកមិនប្រមាទ មិនឃ្លាតចាកសទ្ធម្មឡើយ
មាននិព្វានជាត្រើយ ស្បើយក្តីទុក្ខគ្រប់ប្រការ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ៣០ *( កាសែតទី ៣៤B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវភិក្ខុសេពគប់បក្ខពួកខុសមួយរូប ទើបត្រាស់នូវព្រះគាថានេះថា

**សលាភំ នាតិមញ្ញេយ្យ នាញ្ញេសំ បិហយញ្ចរេ**
**អញ្ញេសំ បិហយំ ភិក្ខុ សមាធឹ នាធិគច្ឆតិ ។**
**អប្បលាភោបិ ចេ ភិក្ខុ សលាភំ នាតិមញ្ញតិ**
**តំ វេ ទេវា បសំសន្តិ សុទ្ធាជីវមតន្ទិតំ ។**

ភិក្ខុមិនគប្បីមើលងាយលាភរបស់ខ្លួន ( ដែលកើតឡើងដោយធម៌ ) មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃ រមែង

មិនបានសមាធិឡើយ ។ បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតានិងមនុស្សទាំងឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាម ជាគ្រឿងអាស្រ័យរស់នៅដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

# បទពាក្យ ៧

ភិក្ខុមិនគួរគប្បីមើលងាយ
រាល់លាភទាំងឡាយជារបស់ខ្លួន
ទោះលាភបានដោយមកតិចចំនួន
កុំផ្ទួនចង់បានលាភរបស់គេ ។
បើចង់បានលាភភិក្ខុដទៃ
ធ្វើឱ្យហឫទ័យអ្នកមិនទំនេរ
សមាធិចិត្តអ្នកក៏គ្មានដែរ
ដូច្នេះត្រូវតែហាត់សង្រួមផ្ទៃ ។
ថាបើអ្នកមិនមើលងាយលាភតិច
មិនភ្លេចព្យាយាមរាល់យប់រាល់ថ្ងៃ

ទេវតានិងមនុស្សជ្រះថ្លាពេកក្រៃ

ស្គាល់គុណតម្លៃនៃជីវិតអ្នក ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ៣១ *( កាសែតទី ៣៥ B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវបញ្ចគ្គទាយកព្រាហ្មណ៍ ទើបត្រាស់នូវព្រះគាថានេះថា

**សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ**
**អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។**

បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាមនិងរូបថាជារបស់អញ ដោយប្រការទាំងពួង មួយទៀតបុគ្គលណាមិនសោកស្តាយ ព្រោះនាមនិងរូបដែលមិនមាន បុគ្គលនោះឯង តថាគតហៅថា ភិក្ខុ ។

# បទពាក្យ ៧

ឈ្មោះថាភិក្ខុក្នុងសាសនា

ហៅឆ្តោះអ្នកណាដែលខ្ជាប់ខ្ជួន

មិនយកនាមរូបថាជាខ្លួន

ថារបស់ខ្លួនឬអត្តា ។

ឬពេលនាមរូបវិនាសទៅ

តែងមិនសោកសៅក្នុងចិន្តា

អ្នកនោះសម្តេចព្រះភគវា

ទ្រង់ឱ្យនាមថាជាភិក្ខុ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៣២ *( កាសែតទី ៣៦ B )*

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ទើបត្រាស់នូវព្រះគាថានេះថា

**មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ**
**អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។**
**សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ**
**ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្វានមេហិសិ ។**
**បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ឧត្តរិ ភាវយេ**
**បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។**

ឈាយ ភិក្ខុ មា ច បមាទោ
មា តេ កាមគុណេ ភមស្សុ ចិត្តំ
មា លោហគុឡំ គិលី បមត្តោ
មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ ។

នត្ថិ ឈានំ អបញ្ញស្ស　នត្ថិ បញ្ញា អឈាយិនោ
យម្ហិ ឈានញ្ច បញ្ញា ច　ស វេ និព្វានសន្តិកេ ។

សុញ្ញាគារំ បវិដ្ឋស្ស　សន្តចិត្តស្ស ភិក្ខុនោ
អមានុសី រតី ហោតិ　សម្មា ធម្មំ វិបស្សតោ ។

យតោ យតោ សម្មសតិ　ខន្ធានំ ឧទយព្វយំ
លភតិ បីតិបាមោជ្ជំ　អមតំ តំ វិជានតំ ។

តត្រាយមាទិ ភវតិ　ឥធ បញ្ញស្ស ភិក្ខុនោ

ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ      បាតិមោក្ខេ ច សំវរោ
មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។
បដិសន្ថារវុត្យស្ស      អាចារកុសលោ សិយា
តតោ បាមោជ្ជពហុលោ ទុក្ខស្សន្តំ ករិស្សសិ ។

ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្ដីសុខ ។

ម្នាលភិក្ខុ ចូរអ្នកស្ដារទូកគឺអត្តភាពនេះ ទូកដែលអ្នកស្ដារហើយ នឹងដល់ត្រើយឆាប់ អ្នកកាត់

រាគៈនិងទោសៈបានហើយ អំពីនោះនឹងអាចដល់នូវព្រះនិព្វាន ។

ភិក្ខុគប្បីកាត់ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់ឧទ្ធម្ភាគិយសំយោជនៈ ៥ ផង គប្បីចម្រើនឥន្ទ្រិយ ៥ តទៅ ភិក្ខុអ្នកកន្លងកិលេស ជាគ្រឿងជំពាក់ ៥ (រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ) បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន ។

ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្តរបស់អ្នក ចូរកុំវិលទៅរកកាម-គុណឡើយ អ្នកចូរកុំប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឱ្យ

ជាអ្នកកាលភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខដូច្នេះឡើយ ។ ការពិនិត្យ មិនមានដល់បុគ្គលអ្នកមិនមានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យនិងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះឯងឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

សេចក្ដីត្រេកអរ ដែលមិនមែនជារបស់មនុស្សរមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់អ្នកឃើញធម៌ដោយប្រពៃ ។

ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ

ភិក្ខុនោះរមែងបានបីតិនិងបាមោជ្ជៈ បីតិនិងបាមោជ្ជៈនោះ ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។

